# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប

សំណុំរឿងព្រហ្មទណ្ឌលេខ:៧៨១
ចុះថ្ងៃទី១០-កក្កដា-២០២២
សំណុំរឿងជំនុំជម្រះលេខ ៦៣៣
ចុះថ្ងៃទី០៥-កញ្ញា-ឆ្នាំ២០២២
សាលក្រមលេខ: ៦៥ "ជ"/៦៧២
ចុះថ្ងៃទី១៣-តុលា-២០២២

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តសៀមរាប។

-កាលបរិច្ឆេទបើកសវនាការថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង ០៩:៣០ នាទី ព្រឹក

-កាលបរិច្ឆេទប្រកាសសាលក្រមថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង០៩:៣០នាទី ព្រឹក ដោយមានសមាសភាពជំនុំជម្រះដូចខាងក្រោម៖

### ក្រុមប្រឹក្សាជំនុំជម្រះ

-លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ

-លោក [redacted] ជាក្រុមប្រឹក្សាជំនុំជម្រះ

-លោក [redacted] ជាក្រុមប្រឹក្សាជំនុំជម្រះ

### តំណាងអយ្យការ

-លោក [redacted] ជាព្រះរាជអាជ្ញារង

### ក្រឡាបញ្ជីសវនាការ

-លោក [redacted] ជាក្រឡាបញ្ជី

### មេធាវី

-លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] អាត។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] អាត។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] អាត ។

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ៧៨១ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាប សំណុំរឿងជំនុំជម្រះលេខ ៦៣៣ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាប ដែលមានជនជាប់ចោទ៖

-ឈ្មោះ [redacted] អាត ភេទប្រុស អាយុ ១៦ឆ្នាំ (កើតថ្ងៃទី០៩ ខែមីនា ឆ្នាំ២០០៦) ជនជាតិខ្មែរ ទីកន្លែងកំណើតស្ថិតនៅភូមិ [redacted] ខេត្តសៀមរាប ទីលំនៅមុនពេលចាប់ខ្លួននៅភូមិព្រៃខ្នារ ឃុំស្រែណូយ ស្រុកវ៉ារិន ខេត្តសៀមរាប មុខរបរ កសិករ កម្រិតវប្បធម៌ថ្នាក់ទី០៣ ឪពុកឈ្មោះ [redacted] អួន "រស់" ម្តាយឈ្មោះ [redacted] ជា "រស់" ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។ (ក្នុងឃុំ)

ជាប់ចោទពីបទៈ លួចដោយមានស្ថានទម្ងន់ទោស (ដោយប្រើអំពើហិង្សា) ប្រព្រឹត្តនៅភូមិព្រៃខ្នារ ឃុំស្រែណូយ ស្រុកវ៉ារិន ខេត្តសៀមរាប កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។



Scanned with CamScanner

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] មុំ ភេទស្រី អាយុ ៥០ឆ្នាំ ទីលំនៅបច្ចុប្បន្នស្ថិតនៅភូមិព្រៃខ្មែរ ឃុំស្រែណូយ ស្រុកវ៉ារិន ខេត្តសៀមរាប ។

## ដំណើររឿងហេតុមានដូចតទៅ

កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង ១២ និង ០០ នាទី ស្ថិតនៅភូមិព្រៃខ្មែរ ឃុំស្រែណូយ ស្រុកវ៉ារិន ខេត្តសៀមរាប ឈ្មោះ [redacted] អាត ភេទប្រុស អាយុ ១៦ឆ្នាំ បានស្ទុះចេញពីព្រៃដំឡូងដៃកាន់ដំបងឈើមួយកំណាត់វាយសំដៅលើជនរងគ្រោះឈ្មោះ [redacted] មុំ ភេទស្រី អាយុ ៥០ឆ្នាំ ជនជាតិខ្មែរមួយដំបងត្រូវចំត្រចៀកខាងស្តាំបណ្តាលឲ្យមុតរយាស់ និងហូរឈាម ធ្វើឲ្យជនរងគ្រោះធ្លាក់ពីលើម៉ូតូ និងដួលសន្លប់ ។ ឈ្មោះ [redacted] អាត ក៏បានយកទូរស័ព្ទដៃមួយគ្រឿងម៉ាក OPPO ពណ៌ទឹកប៊ិច ពីជនរងគ្រោះ រួចរត់គេចខ្លួនចេញទៅបាត់ ។ ក្រោយពីដឹងខ្លួនឡើងវិញជនរងគ្រោះក៏បានទៅដាក់ពាក្យបណ្តឹងនៅសមត្ថកិច្ចដើម្បីចាត់ការតាមនីតិវិធី ។ លុះដល់ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង ០៧ និង០០ នាទីព្រឹក ខណៈពេលដែលឈ្មោះ [redacted] អាត កំពុងតែធ្វើដំណើរចេញពីផ្ទះទៅធ្វើកម្មករស៊ីឈ្នួលគេ ក៏ត្រូវកម្លាំងសមត្ថកិច្ចធ្វើការឃាត់ខ្លួន ។

**បានឃើញ** ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៣៧៥០ ពស.ព្រស/ច ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប។

**បានឃើញ** ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ៦៤៦ ពស.ព្រជ (ក) ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ ២០២២ របស់ប្រធានសាលាដំបូងខេត្តសៀមរាប។

## នាពេលសវនាការ

-ចៅក្រមជំនុំជម្រះផ្ទៀងផ្ទាត់សាវតាជាតិជនជាប់ចោទឈ្មោះ [redacted] អាត ។

-ចៅក្រមជំនុំជម្រះប្រាប់សិទ្ធិជនជាប់ចោទ និងអានឈ្មោះបទល្មើសដែលចោទប្រកាន់ ។

-ជនជាប់ចោទឈ្មោះ [redacted] អាត បានឆ្លើយថា៖ខ្ញុំទទួលស្គាល់បទចោទប្រកាន់ ។

-ចៅក្រមជំនុំជម្រះអានអង្គហេតុនៃរឿងក្តី ។

-ជនជាប់ចោទឈ្មោះ [redacted] អាត បានឆ្លើយថា៖ ខ្ញុំទទួលស្គាល់បទចោទប្រកាន់ ខ្ញុំស្គាល់ជនរងគ្រោះជាអ្នកភូមិជាមួយគ្នា ។ ខ្ញុំចង់បានទូរស័ព្ទទើបវាយយកទូរស័ព្ទរបស់ជនរងគ្រោះ ។ ខ្ញុំប្រព្រឹត្តតែម្នាក់ឯងទេ ។ ខ្ញុំវាយគាត់ចំពីក្រោយដោយវាយល្មមៗ ។ ខ្ញុំមិនចេះប្រើគ្រឿងញៀនទេ ។ ខ្ញុំគិតចំនួន ២ថ្ងៃមុនធ្វើសកម្មភាព ។ ខ្ញុំលួចយកទូរស័ព្ទទៅប្រើទេ ខ្ញុំមិនធ្លាប់លួចអ្នកផ្សេងទេ ។ ទូរស័ព្ទអោយគេវិញហើយ ។ ខ្ញុំវាយនឹងមែកចន្ទី ខ្ញុំវាយមួយដំបងគាត់សន្លប់ខ្ញុំយកតែទូរស័ព្ទទេ។ លុះព្រឹកឡើងបន្ទាប់ពីថ្ងៃកើតហេតុគេក៏មកចាប់ខ្ញុំ ។ ខ្ញុំវាយជនរងគ្រោះហើយទុកចោលក្នុងព្រៃ ។ ខ្ញុំគិតថាគេស្លាប់ ។ ខ្ញុំរៀនថ្នាក់ទី ១ ។ ដំបងខ្ញុំរើសបាន ខ្ញុំរើសបាននៅថ្ងៃកើតហេតុ ។ ទូរស័ព្ទរបស់ជនរងគ្រោះអត់មានលេខកូដទេ ខ្ញុំមិនស្គាល់ម៉ាកវានោះទេ ។ ខ្ញុំឃើញគាត់កាន់ទូរស័ព្ទទើបដឹងថាគាត់មានទូរស័ព្ទ ។ ខ្ញុំទើបតែលួចលើកទី ១ ។ ខ្ញុំវាយជនរង-គ្រោះចង់បានតែទូរស័ព្ទទេ ហើយវាយតិចតួចទេ ។ ខ្ញុំលួចទូរស័ព្ទមកលេង ។

-ដើមបណ្តឹងរដ្ឋប្បវេណីនិងជាជនរងគ្រោះឈ្មោះ [redacted] មុំ បានឆ្លើយថា៖ នៅថ្ងៃកើតហេតុពេលខ្ញុំជិះម៉ូតូជនជាប់ចោទបានមកវាយ និងប្រតាយប្រតប់ជាមួយខ្ញុំ រួចខ្ញុំបុកមែកចន្ទី ហើយចេញឈាម ទើបខ្ញុំសន្លប់ ។ ខ្ញុំមិនទាមទារអ្វីទេ ពេលខ្ញុំជិះម៉ូតូជនជាប់ចោទរកវាយខ្ញុំ ពេលនោះខ្ញុំក៏ប្រតាយប្រតប់ទើបហូរឈាមហើយ ក៏ដួលសន្លប់ ពេលដឹងខ្លួនខ្ញុំជិះម៉ូតូទៅផ្ទះ ។ ខ្ញុំដួលចំហៀងម៉ូតូ ។



Scanned with CamScanner

-មន្ត្រីនគរបាលយុត្តិធម៌លោក [redacted] រាក់ បានឆ្លើយថា៖ជនជាប់ចោទគឺវាពួនស្ទាក់វាយជនរងគ្រោះចេញឈាមហើយសន្លប់ ពេលភ្ញាក់ទើបប្រាប់ប្តីឲ្យដាក់ពាក្យបណ្តឹង ។ នៅថ្ងៃកើតហេតុជនជាប់ចោទបានបើកគោយន្តកន្ត្រៃទៅដកដំឡូងអោយគេ ពេលដកដំឡូងហើយ វាក៏អង្គុយលើគោយន្ត ពេលនោះស្រាប់តែវាបានឃើញជនរងគ្រោះបើកម៉ូតូមក ហើយវាក៏បានទៅពួនស្ទាក់វាយជនរងគ្រោះដើម្បីយកទូរស័ព្ទ ។ វាវាយជនរងគ្រោះម្នាក់ឯង ជនជាប់ចោទអង្គុយលើគោយន្តម្នាក់ឯង រំលងបានមួយថ្ងៃទើបចាប់វាបាន ។ ពេលវាបានទូរស័ព្ទហើយវាបានយកទៅដើរបង្អួតអ្នកជិតខាង ហើយក៏បែករឿងវាវាយគេយកទូរស័ព្ទ ទើបសមត្ថកិច្ចបានចុះទៅធ្វើការឃាត់ខ្លួនតែម្តង ។

-សាក្សីឈ្មោះ [redacted] ឈាងឡាយ បានឆ្លើយថា៖ ខ្ញុំដឹងត្រឹមថាមានអ្នកសួរខ្ញុំថាមានក្មេងដើរកាត់ទេ ខ្ញុំឆ្លើយថាឃើញក្មេងម្នាក់ដើរកាត់ ។

-សាក្សីឈ្មោះ [redacted] សុចិត្ត បានឆ្លើយថា៖ ខ្ញុំជាប្តីរបស់ជនរងគ្រោះ ។ នៅថ្ងៃកើតហេតុប្រពន្ធរបស់ខ្ញុំបានជិះម៉ូតូទៅចម្ការ ស្រាប់តែត្រូវជនជាប់ចោទឈ្មោះ [redacted] អាត បានពួនស្ទាក់រកវាយដើម្បីលួចទូរស័ព្ទ ពេលនោះប្រពន្ធរបស់ខ្ញុំបានប្រតាយប្រតប់គ្នាជាមួយជនជាប់ចោទ ហើយក៏មុតមែកចន្ទី បណ្តាលអោយគាត់ចេញឈាម រួចគាត់ក៏សន្លប់បាត់ទៅ ។ ពេលគាត់ដឹងខ្លួនមកវិញគាត់បានជិះម៉ូតូមកប្រាប់ខ្ញុំ ហើយខ្ញុំក៏ដាក់ពាក្យបណ្តឹងតែម្តង ។

-ជនជាប់ចោទឈ្មោះ [redacted] អាត បានឆ្លើយថា៖ ខ្ញុំគ្មានអ្វីបន្ថែមទៀតទេ ។

-សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការថា៖ ក្រោយស្តាប់កិច្ចពិភាក្សាដេញដោលនៅក្នុងពេលសវនាការឃើញថា ជនជាប់ចោទឈ្មោះ [redacted] អាត បានឆ្លើយសារភាពថាខ្លួនពិតជាបានពួនស្ទាក់វាយទៅលើជនរងគ្រោះមួយដំបងបណ្តាលអោយសន្លប់ដើម្បីលួចយកទូរស័ព្ទរបស់ជនរងគ្រោះពិតប្រាកដមែន បើទោះបីចម្លើយរបស់ជនរងគ្រោះឆ្លើយថា គ្រាន់តែជាការប្រតាយប្រតប់គ្នាហើយមុតមែកឈើបណ្តាលអោយហូរឈាមហើយដួលសន្លប់ក៏ដោយ តែចម្លើយនេះហាក់មានការឆ្លើយដើម្បីដោះបន្ទុកអោយជនជាប់ចោទប៉ុណ្ណោះ ព្រោះបើតាមចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលបានចុះទៅកន្លែងកើតហេតុ និងភស្តុតាងដែលមាននៅក្នុងសំណុំរឿងបង្ហាញថាជនជាប់ចោទបានវាយទៅលើជនរងគ្រោះមិនមែនជាការប្រតាយប្រតប់គ្នានោះទេ ។ អំពើរបស់ជនជាប់ចោទមានជាតុផ្សំបទល្មើសគ្រប់គ្រាន់ពីបទ លួចមានស្ថានទម្ងន់ទោស ហេតុដូច្នេះ តំណាងអយ្យការស្នើសុំចៅក្រមជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] អាត ពីបទលួចមានស្ថានទម្ងន់ទោស តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] អាត បានធ្វើសេចក្តីសន្និដ្ឋានថា៖ក្រោយពីស្តាប់កិច្ចពិភាក្សាដេញដោលក្នុងពេលសវនាការឃើញថា កូនក្តីរបស់ខ្ញុំ បានឆ្លើយសារភាពថាខ្លួនពិតជាបានពួនស្ទាក់វាយយកទូរស័ព្ទរបស់ជនរងគ្រោះពិតប្រាកដមែន ប៉ុន្តែក្នុងគោលបំណងដើម្បីតែយកមកលើហ្គេមតែប៉ុណ្ណោះ ហើយដូចអ្វីដែលកូនក្តីខ្ញុំបានបញ្ជាក់គាត់រៀនបានត្រឹមថ្នាក់ទី ១ ប៉ុណ្ណោះដែលការគិតរបស់គាត់គឺមិនបានវែងឆ្ងាយ ទើបប្រព្រឹត្តអំពើបែបនោះ ហើយក្រោយពេលដែលគាត់លួចបានគាត់មិនបានយកទូរស័ព្ទនោះទៅលក់យកលុយនោះទេ បែរជាទៅដើរអួតអ្នកដទៃ ដែលនេះបង្ហាញអោយឃើញថាការគិតរបស់គាត់គឺមិនមានគំនិតអ្វីក្រៅពីការយកទូរស័ព្ទទៅលេងនោះទេ ហើយដើមបណ្តឹងបានដកពាក្យបណ្តឹងឈប់ប្តឹងកូនក្តីខ្ញុំទៀតហើយ ហេតុដូច្នេះក្នុងមានជាមេធាវីការពារសិទ្ធិជនជាប់ចោទខ្ញុំស្នើសុំចៅក្រមក្រុមប្រឹក្សាសម្រេចផ្តល់ស្ថានសម្រាលទោសដល់កូនក្តីខ្ញុំបាទ និងព្យួរទោសមួយផ្នែកដល់កូនក្តីខ្ញុំបាទ ។



Scanned with CamScanner

-លោក [redacted] ជាមេធាវីការពារសិទ្ធិជនជាប់ចោទឈ្មោះ [redacted] អាត បានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយស្តាប់កិច្ចពិភាក្សាដេញដោលក្នុងពេលសវនាការឃើញថា ដោយហេតុថាកូនក្តីរបស់ខ្ញុំបាទជាអនីតិជន ហើយរៀនថ្នាក់ទី ១ អំពើប្រព្រឹត្តរបស់គាត់មិនមែនជាកំហុសរបស់គាត់តែម្នាក់នោះទេ វាជាការចូលរួមពីសង្គម និងអាណាព្យាបាលផងដែល មនុស្សម្នាក់នៅពេលដែលគាត់ទទួលបានការអប់រំទាបធ្វើអោយការគិតនៅមានកម្រិតខ្លី ជាក់ស្តែងដូចដែលបានឃើញហើយថា គាត់វាយដើម្បីយកទូរស័ព្ទទៅលេងហ្គេម និងមិនមានចេតនារត់គេចខ្លួនទេ បែរជាទៅដើរបង្អួតគេ នេះបង្ហាញថាកម្រិតការយល់ដឹងរបស់គាត់នៅមានកម្រិតទាបមែនទែន ហេតុដូច្នេះស្នើសុំលោកចៅក្រមពិនិត្យពិចារណាសម្រេចផ្តន្ទាទោសលើកូនក្តីខ្ញុំបាទក្នុងកម្រិតអប្បរមា ។

-ជនជាប់ចោទឈ្មោះ [redacted] អាត បានឆ្លើយសំដីចុងក្រោយថា៖ ខ្ញុំសូមសំណូមពរតុលាការមេត្តាបន្ធូរបន្ថយទោសដល់រូបខ្ញុំផង ។

-ក្រោយពីស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីស្តាប់ចម្លើយមន្ត្រីនគរបាលយុត្តិធម៌

-ក្រោយពីស្តាប់ចម្លើយសាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

តាមលទ្ធផលនៃកិច្ចពិភាក្សាដេញដោល និងពិនិត្យភស្តុតាងនាពេលសវនាការឃើញថា៖

១-ឆ្លងតាមកិច្ចពិភាក្សាដេញដោលនាពេលសវនាការ ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ចម្លើយសាក្សី ចម្លើយមន្ត្រីនគរបាលយុត្តិធម៌ ភស្តុតាងនានា និងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ជាដើមឃើញថាពិតជាមានអង្គហេតុនៃអំពើ លួចដោយមានស្ថានទម្ងន់ទោស (ដោយប្រើអំពើហិង្សា) ប្រព្រឹត្តនៅភូមិព្រៃខ្នុរ ឃុំស្រែណូយ ស្រុកវ៉ារិន ខេត្តសៀមរាប កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ពិតមែន ។

២-តាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] មុំ បានឆ្លើយនៅគ្រប់ដំណាក់កាលនីតិវិធីរបស់តុលាការថា៖ កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២២ ម៉ោងប្រហែលជា ដប់ពីរ ថ្ងៃ ខ្លួនបានជិះម៉ូតូម៉ាក វីវ៉ា ម្នាក់ឯង ចេញពីកន្លែងធ្វើការទៅផ្ទះ ពេលជិះដល់ចំការដំឡូង ស្រាប់តែឈ្មោះ [redacted] អាត បានកាន់ដំបងឈើមែកចន្ទីប៉ុនកដៃ ស្ទុះចេញពីចំការដំឡូងមីមកវាយខ្លួនមួយដំបងចំក្បាលជិតត្រចៀកខាងស្តាំ បណ្តាលខ្លួនដួលទៅនឹងដី ហើយវាក៏ចូលមកប្រតាយប្រតប់ជាមួយខ្លួន និងបានយកទូរស័ព្ទពីខ្លួន មួយគ្រឿងម៉ាក oppo ពណ៌ខៀវ រួចវាក៏ចេញទៅបាត់ទៅ ។ ខ្លួនមិនដែលមានទំនាស់ និងស្គាល់ឈ្មោះ [redacted] អាត ទេ ស្គាល់តែម្តាយរបស់ឈ្មោះ [redacted] អាត ជាកម្មករស៊ីឈ្នួលគេជាមួយគ្នា ។ ក្រៅពីទូរស័ព្ទឈ្មោះ [redacted] អាត មិនបានយកអ្វីពីខ្លួនទៀតទេ ។ ខ្លួនត្រូវរបួសក្បាលជិតត្រចៀកខាងស្តាំ ដេរអស់ ប្រាំពីរថ្នេរ ហើយម្តាយរបស់ឈ្មោះ [redacted] អាត គាត់បានចេញថ្លៃថ្នាំព្យាបាលឲ្យខ្លួនរួចហើយចំនួនពីរលានរៀល ។ ក្នុងរឿងនេះខ្លួនបានដកពាក្យ



Scanned with CamScanner

បណ្តឹងរួចហើយ មិនទាមទារអ្វីទៀតទេ ព្រោះគ្រួសារឈ្មោះ [redacted] អាត គាត់ក្រីក្រណាស់ ហើយខ្លួន និង គាត់ក៏មិនដែលមានរឿងដែរពីមុន ។

ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] មុំ មានភាពស៊ីសង្វាក់ជាមួយចម្លើយជនជាប់ចោទ ឈ្មោះ [redacted] អាត ចម្លើយសាក្សីឈ្មោះ [redacted] សុចិត្ត ចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌ឈ្មោះ [redacted] រាក់ ព្រម ទាំងស្របជាមួយភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿង ហេតុដូច្នេះចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] មុំ មានភាពជួនល្មមអាចអោយតុលាការជឿជាក់បាន ។

៣-តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] អាត បានឆ្លើយនៅគ្រប់ដំណាក់កាលនីតិវិធី របស់តុលាការថា៖ខ្លួនទទួលស្គាល់ថា បានប្រព្រឹត្តអំពើដូចការចោទប្រកាន់មែន ។ មូលហេតុដែលខ្លួនប្រព្រឹត្ត អំពើលួចដោយប្រើប្រាស់ហិង្សាគឺ ដោយសារខ្លួនចង់បានទូរស័ព្ទយកទៅលេង ដោយកាលពីថ្ងៃទី០៨ ខែ កក្កដា ឆ្នាំ២០២២ វេលាម៉ោង ១២ និង ០០ នាទី ខ្លួនបានឃើញជនរងគ្រោះជិះម៉ូតូម្នាក់ឯង ក៏ពួនក្នុង ចំការដំឡូង ដៃកាន់ដំបងឈើមួយកំណាត់ ហើយជនរងគ្រោះមកដល់ក៏ស្ទុះវាយលើជនរងគ្រោះ ចំផ្នែកខាង ក្រោយមួយទំហឹងបណ្តាលឲ្យជនរងគ្រោះដួលម៉ូតូទៅនឹងដី ហើយខ្លួនក៏បានយកទូរស័ព្ទជនរងគ្រោះរួចគេច ខ្លួនទៅផ្ទះ លេងទូរស័ព្ទ ហើយស្អែកព្រឹកក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួននៅផ្ទះតែម្តង ។ ក្រៅពីទូរស័ព្ទខ្លួនមិនបាន លួចអ្វីទៀតទេ ។ ខ្លួនទើបតែប្រព្រឹត្តលើកទី១ ដោយសារចង់បានទូរស័ព្ទប្រើប្រាស់ ។ សមត្ថកិច្ចដកហូតពី ខ្លួនមានឈើកំណាត់ដែលខ្លួនប្រើវាយលើជនរងគ្រោះមួយ និងទូរស័ព្ទដែលលួចពីជនរងគ្រោះ ។ សំណូមពរ សូមឲ្យតុលាការបន្ធូរបន្ថយទោសដល់ខ្លួនផង ខ្លួនដឹងខុសហើយ ។

ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] អាត ជាចម្លើយសារភាពដែលផុសចេញពីចេតនារបស់ខ្លួនពិត ប្រាកដ ដោយពុំមានការគម្រាមកំហែងត្រង់ចំណុចណាមួយនោះទេ ហើយចម្លើយនេះមានភាពស៊ីសង្វាក់ជា មួយចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] មុំ ចម្លើយសាក្សីឈ្មោះ [redacted] សុចិត្ត ចម្លើយមន្ត្រីនគរបាល-យុត្តិធម៌ឈ្មោះ [redacted] រាក់ ព្រមទាំងស្របជាមួយអង្គហេតុ និងភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿង ហេតុដូច្នេះចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] អាត មានភាពជួនល្មមអាចអោយតុលាការជឿជាក់ បាន ។

៤-តាមចម្លើយសាក្សីឈ្មោះ [redacted] សុចិត្ត បានឆ្លើយនៅដំណាក់កាលចៅក្រមជំនុំជម្រះថា៖ ខ្លួនជាប្តី របស់ជនរងគ្រោះ ។ នៅថ្ងៃកើតហេតុប្រពន្ធរបស់ខ្លួនបានជិះម៉ូតូទៅចម្ការ ស្រាប់តែត្រូវជនជាប់ចោទឈ្មោះ [redacted] អាត បានពួនស្ទាក់រកវាយដើម្បីលួចទូរស័ព្ទ ពេលនោះប្រពន្ធរបស់ខ្លួនបានប្រតាយប្រតប់គ្នាជាមួយ ជនជាប់ចោទ ហើយក៏មុតមែកចទ្ទី បណ្តាលអោយគាត់ចេញឈាម រួចគាត់ក៏សន្លប់បាត់ទៅ ។ ពេលគាត់ ដឹងខ្លួនមកវិញគាត់បានជិះម៉ូតូមកប្រាប់ខ្លួន ហើយខ្លួនក៏ដាក់ពាក្យបណ្តឹងតែម្តង ។

ចម្លើយសាក្សីឈ្មោះ [redacted] សុចិត្ត មានភាពស៊ីសង្វាក់ជាមួយចម្លើយជនជាប់ចោទឈ្មោះ [redacted] អាត ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] មុំ ចម្លើយមន្ត្រីនគរបាលយុត្តិធម៌ឈ្មោះ [redacted] រាក់ ព្រមទាំងស្របជា មួយអង្គហេតុ និងភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿង ហេតុដូច្នេះចម្លើយរបស់សាក្សីឈ្មោះ [redacted] សុចិត្ត មានភាពជួនល្មមអាចអោយតុលាការជឿជាក់បាន ។

៥-តាមចម្លើយមន្ត្រីនគរបាលយុត្តិធម៌ឈ្មោះ [redacted] រាក់ បានឆ្លើយនៅដំណាក់កាលចៅក្រមជំនុំជម្រះ ថា៖ ជនជាប់ចោទគឺវាពួនស្ទាក់វាយជនរងគ្រោះចេញឈាមហើយសន្លប់ ពេលភ្ញាក់ទើបប្រាប់ប្តីឲ្យដាក់ពាក្យ បណ្តឹង ។ នៅថ្ងៃកើតហេតុជនជាប់ចោទបានបើកគោយន្តកន្ត្រៃទៅដកដំឡូងអោយគេ ពេលដកដំឡូង

ហើយ វាក៏អង្គុយលើគោយន្ត ពេលនោះស្រាប់តែវាបានឃើញជនរងគ្រោះបើកម៉ូតូមក ហើយវាក៏បានទៅពួនស្ទាក់វាយជនរងគ្រោះដើម្បីយកទូរស័ព្ទ ។ វាវាយជនរងគ្រោះម្នាក់ឯង ជនជាប់ចោទអង្គុយលើគោយន្តម្នាក់ឯង រំលងបានមួយថ្ងៃទើបចាប់វាបាន ។ ពេលវាបានទូរស័ព្ទហើយវាបានយកទៅដើរបង្អួតអ្នកជិតខាង ហើយក៏បែករឿងវាវាយគេយកទូរស័ព្ទ ទើបសមត្ថកិច្ចបានចុះទៅធ្វើការឃាត់ខ្លួនតែម្តង ។

ចម្លើយមន្ត្រីនគរបាលយុត្តិធម៌ឈ្មោះ [redacted] រាក់ មានភាពស៊ីសង្វាក់ជាមួយចម្លើយជនជាប់ចោទឈ្មោះ [redacted] អាត ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] មុំ ចម្លើយសាក្សីឈ្មោះ [redacted] សុចិត្ត ព្រមទាំងស្របជាមួយអង្គហេតុ និងភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿង ហេតុដូច្នេះចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌ឈ្មោះ ទិញ រាក់ មានភាពជួនល្មមអាចអោយតុលាការជឿជាក់បាន ។

៦-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] អាត ដែលបានពួនស្ទាក់វាយដោយដំបងឈើទៅលើជនរងគ្រោះឈ្មោះ [redacted] មុំ បណ្តាលអោយសន្លប់រួចបានលួចយកទូរស័ព្ទដៃរបស់ជនរងគ្រោះ ដើម្បីយកមកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន មានធាតុផ្សំបទល្មើសគ្រប់គ្រាន់ពីបទ លួចដោយមានស្ថានទម្ងន់ទោស (ដោយប្រើអំពើហិង្សា) បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៧-ផ្អែកតាមចម្លើយសារភាពរបស់ជនជាប់ចោទ ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ចម្លើយសាក្សី ចម្លើយមន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងភស្តុតាងដែលមានក្នុងសំណុំរឿង ឃើញថាមានភាពស៊ីសង្វាក់គ្នាដែលបញ្ជាក់បានថាជនជាប់ចោទឈ្មោះ [redacted] អាត ពិតជាបានប្រព្រឹត្តអំពើ លួចដោយមានស្ថានទម្ងន់ទោស (ដោយប្រើអំពើហិង្សា) ប្រព្រឹត្តនៅភូមិព្រៃខ្នុរ ឃុំស្រែណូយ ស្រុកវ៉ារិន ខេត្តសៀមរាប កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៨-មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] អាត ភេទប្រុស អាយុ ១៦ឆ្នាំ ជនជាតិខ្មែរ ជាប់ចោទពីបទ លួចដោយមានស្ថានទម្ងន់ទោស (ដោយប្រើអំពើហិង្សា) ប្រព្រឹត្តនៅភូមិព្រៃខ្នុរ ឃុំស្រែណូយ ស្រុកវ៉ារិន ខេត្តសៀមរាប កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៩-ជនជាប់ចោទឈ្មោះ [redacted] អាត ភេទប្រុស អាយុ ១៦ឆ្នាំ ជនជាតិខ្មែរ ជាអនីតិជនមានបុគ្គលិកលក្ខណៈគ្រប់គ្រាន់តាមផ្លូវច្បាប់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌបាន ។ ជនជាប់ចោទមានសមត្ថភាពខាងធន្ទៈ ឬមានស្មារតីល្អគ្រប់គ្រាន់ដែលអាចយល់ដឹង និង វិនិច្ឆ័យបានអំពីលទ្ធផលកើតចេញពីអំពើដែលខ្លួនបានប្រព្រឹត្ត ។

១០-យោងបញ្ញត្តិមាត្រា ១៦០ កថាខណ្ឌ ១ ចំណុច ១ និងចំណុច ៣ (មូលទោសអនុវត្តចំពោះអនីតិជនអាយុចាប់ពី ១៤ ឆ្នាំ ឡើងទៅ) នៃក្រមព្រហ្មទណ្ឌបានចែងថា៖ កាលណាតុលាការសម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ មូលទោសលើបទល្មើសដែលចោទប្រកាន់ ត្រូវបានបន្ថយក្នុងលក្ខខណ្ឌដូចតទៅ :

-អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល ។

-អប្បបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្តាល ប្រសិនបើអប្បបរមានេះលើសពី ១ (មួយ) ថ្ងៃ ។



Scanned with CamScanner

ហេតុដូច្នេះតុលាការគប្បីពិចារណាផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] អាត ភេទប្រុស អាយុ ១៦ឆ្នាំ ជនជាតិខ្មែរ ស្របតាមបញ្ញត្តិមាត្រា ១៦០ កថាខណ្ឌ ១ ចំណុច ១ និងចំណុច ៣ នៃក្រមព្រហ្មទណ្ឌ ។

១១-សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការថា ក្រោយស្តាប់កិច្ចពិភាក្សាដេញដោលនៅក្នុងពេលសវនាការឃើញថា ជនជាប់ចោទឈ្មោះ [redacted] អាត បានឆ្លើយសារភាពថាខ្លួនពិតជាបានពួនស្ទាក់វាយទៅលើជនរងគ្រោះមួយដំបងបណ្តាលអោយសន្លប់ដើម្បីលួចយកទ្រព្យសម្បត្តិរបស់ជនរងគ្រោះពិតប្រាកដមែន បើទោះបីចម្លើយរបស់ជនរងគ្រោះឆ្លើយថា គ្រាន់តែជាការប្រតាយប្រតប់គ្នាហើយមុតមែកឈើបណ្តាលអោយហូរឈាមហើយដួលសន្លប់ក៏ដោយ តែចម្លើយនេះហាក់មានការឆ្លើយដើម្បីដោះបន្ទុកអោយជនជាប់ចោទប៉ុណ្ណោះ ព្រោះបើតាមចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលបានចុះទៅកន្លែងកើតហេតុ និងភស្តុតាងដែលមាននៅក្នុងសំណុំរឿងបង្ហាញថាជនជាប់ចោទបានវាយទៅលើជនរងគ្រោះមិនមែនជាការប្រតាយប្រតប់គ្នានោះទេ ។ អំពើរបស់ជនជាប់ចោទមានធាតុផ្សំបទល្មើសគ្រប់គ្រាន់ពីបទ លួចមានស្ថានទម្ងន់ទោស ហេតុដូច្នេះ តំណាងអយ្យការស្នើសុំចៅក្រមជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] អាត ពីបទលួចមានស្ថានទម្ងន់ទោស តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

-តុលាការយល់ឃើញថាសេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ មានលក្ខណៈត្រឹមត្រូវដែលគប្បីពិចារណា។

## ហេតុដូច្នេះសម្រេច

**-ផ្តន្ទាទោសជនជាប់ចោទ៖**

-ឈ្មោះ [redacted] អាត ភេទប្រុស អាយុ ១៦ឆ្នាំ កើតថ្ងៃទី០៩ ខែមីនា ឆ្នាំ២០០៦ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ២ (ពីរ) ឆ្នាំ ។

ពីបទ លួចដោយមានស្ថានទម្ងន់ទោស (ដោយប្រើអំពើហិង្សា) ប្រព្រឹត្តនៅភូមិព្រៃខ្នុរ ឃុំស្រែណូយ ស្រុកវ៉ារិន ខេត្តសៀមរាប កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

-សាលក្រមនេះជំនុំជម្រះ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] អាត និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] មុំ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២ ។

-ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមក្រុមប្រឹក្សា** | **ចៅក្រមក្រុមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខ | ហត្ថលេខា | ហត្ថលេខា និងត្រា |

[redacted]

---

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ៣រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

សៀមរាប ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២

**ក្រឡាបញ្ជីសវនាការ**

[redacted]



Scanned with CamScanner